

កូនប្រុសបះបោរសុំមរតករបស់គាត់ ហើយចេញពីផ្ទះ ។

គាត់ខ្ជះខ្ជាយអ្វីៗគ្រប់យ៉ាងដែលឪពុករបស់គាត់ផ្ដល់ឲ្យគាត់ទៅលើរឿងសប្បាយរីករាយ ។

គ្រោះទុរភិក្សបានកើតឡើង ដូច្នេះគាត់ក៏ធ្វើការជាអ្នកឲ្យចំណីសត្វជ្រូក ។

# កូន ខ្ជះខ្ជាយ



នៅថ្ងៃមួយគាត់ដឹងថា គាត់អាចទៅផ្ទះ ហើយសុំជំនួយបាន ។

នៅពេលគាត់ត្រឡប់មកផ្ទះវិញ គាត់សុំធ្វើជាអ្នកបម្រើក្នុងគ្រួសាររបស់គាត់ ដោយមិនគិតថាគាត់នឹងទទួលបានការចាត់ទុកជាកូនប្រុសរបស់ឪពុកគាត់តទៅទៀតនោះទេ ។



ប៉ុន្តែឪពុករបស់គាត់បានអត់ទោសឲ្យកូនខ្ជះខ្ជាយនោះ ហើយទទួលយកកូននោះជាកូនរបស់គាត់ ហើយគ្រួសារក៏ប្រារព្ធពិធីអបអរដែលកូនប្រុសនោះត្រឡប់មកវិញ ។

## តើវាមានន័យយ៉ាងណា

កូនខ្ជះខ្ជាយតំណាងឲ្យយើង នៅពេលយើងបះបោរប្រឆាំងនឹងព្រះវរបិតាសួគ៌របស់យើង ។ ប៉ុន្តែមិនថាយើងបានទៅដល់ទីណា ឬអ្វីដែលយើងបានធ្វើនោះទេ ព្រះវរបិតាសួគ៌ចង់ឲ្យយើងត្រឡប់មកផ្ទះវិញមករកទ្រង់ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

យើងពុំចាំបាច់ល្អឥតខ្ចោះនោះទេ ។ យើងត្រូវតែមានវិប្បដិសារី និងបន្ទាបខ្លួន មករកព្រះគ្រីស្ទ ហើយប្រែចិត្ត ។ ព្រះនឹងធ្វើឲ្យយើងមានសីល្ធ ហើយបង្ហាញយើងពីភាពស័ក្តិសមដ៏ពិតរបស់យើង ។

រចនារូបភាពដោយ អ៊ីថាន ហេហ្គើង